# ផន្ទនជាតក

## (រឿងពៀររបស់ខ្លាឃ្មុំនិងដើមពង្រ)





*ព្រះសាស្តា កាលស្តេចគង់នៅនឹងច្រាំងស្ទឹងរោហិណី ទ្រង់ប្រារព្ធការឈ្លោះរបស់ពពួកញាតិ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **កុឋារិហត្ថោ បុរិសោ** *ដូច្នេះជាដើម ។*

*រឿងរ៉ាវបច្ចុប្បន្នក្នុងជាតកនេះ នឹងមានជាក់ច្បាស់ក្នុង* ***កុណាលជាតក*** *។*

*គ្រានោះ ព្រះសាស្តាហៅពពួកញាតិមកហើយ ត្រាស់ថា បពិត្រមហារាជ ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី នៅខាងក្រៅនគរ មានស្រុកជាងឈើមួយ ។* ***វឌ្ឍកីព្រាហ្មណ៍*** *(ព្រាហ្មណ៍ជាជាងឈើ) ម្នាក់នាំយកឈើអំពីព្រៃ មកធ្វើរថ*

*ដើម្បីចិញ្ចឹមជីវិត ។ គ្រានោះ មានដើមពង្រដ៏ធំមួយ ក្នុងហិមវន្តប្រទេស ។* ***កាឡសីហៈ*** *(ខ្លាឃ្មុំ) មួយ ត្រាច់ស្វែងរកអាហារ បានមកដេកនៅនឹងគល់ដើមពង្រនោះ ។*

*ថ្ងៃមួយ កាលខ្យល់បក់ខ្លាំង ធ្វើឲ្យមែកស្ងួតបាក់ ធ្លាក់ត្រូវកខ្លាឃ្មុំ ។ ខ្លាឃ្មុំមុតនឹងកំណាត់ឈើបន្តិច ភ័យខ្លាច ក្រោកឡើង ស្ទុះរត់ចេញ ហើយត្រឡប់ងាកមើលផ្លូវដែលមក មិនឃើញអ្វីឡើយ ទើបគិតថា សីហៈ ខ្លា ឬ សត្វដទៃ ដែលដេញតាមយើងមិនមាន ទេវតាដែលកើតនៅនឹងដើមឈើនេះ ប្រហែលជាមិនចង់ឲ្យយើងដេកក្នុងទីនេះ ចាំមើលចុះ គង់នឹងបានដឹងគ្នា ដូច្នេះក៏ចងក្រោធក្នុងហេតុដែលមិនគួរ ហើយប្រហារដើមឈើ គំរាមរុក្ខទេវតាថា យើងមិនបានស៊ីស្លឹក និងមិនបានស៊ីមែកដើមឈើរបស់អ្នកទេ ម្រឹគដទៃមកដេកត្រង់នេះ អ្នកអត់ធន់បាន តែយើង អ្នកអត់ធន់មិនបាន ទោសដូចម្ដេចមានដល់យើង (ចាំមើល) កន្លងទៅពីរបីថ្ងៃទៀត យើងនឹងឲ្យគេមកដកដើមឈើរបស់អ្នកព្រមទាំងគល់ យើងនឹងគេកាត់ជាកំណាត់តូចជាកំណាត់ធំ ដូច្នេះហើយ កាលរកមើលបុរស ទើបត្រាច់ទៅ ។*

*គ្រានោះ វឌ្ឍកីព្រាហ្មណ៍នាំមនុស្សពីរបីនាក់ទៅកាន់ប្រទេសនោះដោយយាន ដើម្បីរកឈើមកធ្វើរថ បានឈប់យាននៅកន្លែងមួយ ជាអ្នកមានដៃកាន់កាំបិត និងពូថៅ កាលរកមើលដើមឈើ ក៏បានទៅដល់ទីជិតដើមពង្រនោះ ។ កាឡសីហៈឃើញព្រាហ្មណ៍នោះហើយគិតថា ថ្ងៃនេះ គួរនឹងបានឃើញខ្នងសត្រូវរបស់យើង ដូច្នេះក៏ទៅឈរជិតគល់ដើមឈើ ។ ជាងឈើសម្លឹងមើលខាងនេះខាងនោះ បានទៅដល់ទីជិតដើមពង្រ ។ កាឡសីហៈគិតថា ជាងឈើនេះមិនទាន់កន្លងហួសទៅដរាបណា យើងប្រាប់គេដរាបនោះ ដូច្នេះហើយ ក៏ពោលគាថាទី ១ ថា*

**កុឋារិហត្ថោ បុរិសោ, វនមោគយ្ហ តិដ្ឋសិ;**
**បុដ្ឋោ មេ សម្ម អក្ខាហិ, កឹ ទារុំ ឆេតុមិច្ឆសិ។**

*អ្នកជាបុរសមានដឹងក្នុងដៃ ចូលមកឈរនៅក្នុងព្រៃ នែសម្លាញ់ ខ្ញុំសួរហើយ ចូរអ្នកប្រាប់ តើអ្នកចង់កាប់ឈើអ្វី ។*

វឌ្ឍកីព្រាហ្មណ៍ស្តាប់ពាក្យរបស់ខ្លាឃ្មុំហើយ គិតថា ឱហ្ន៎ ពិតជាអស្ចារ្យណាស់ ម្រឹគនិយាយវាចាមនុស្ស យើងមិនធ្លាប់ជួបក្នុងកាលមុនឡើយ ម្រឹគនេះគង់ដឹងឈើដែលសមគួរធ្វើរថ យើងនឹងសួរម្រឹគនោះ ដូច្នេះទើបពោលគាថាទី ២ ថា

**ឥស្សោ វនានិ ចរសិ, សមានិ វិសមានិ ច;**
**បុដ្ឋោ មេ សម្ម អក្ខាហិ, កឹ ទារុំ នេមិយា ទឡ្ហំ។**

***អ្នកជាកាឡសីហៈ ត្រាច់ទៅកាន់ព្រៃស្មើ និងមិនស្មើ ម្នាលសម្លាញ់ ខ្ញុំសួរហើយ អ្នកចូរប្រាប់ឈើអ្វី ធ្វើខ្នងកង់ ជាប់មាំ ។***

*កាឡសីហៈស្តាប់ពាក្យនោះហើយ គិតថា ឥឡូវនេះ មនោរថរបស់យើងនឹងដល់ទីបំផុត ដូច្នេះទើបពោលគាថាទី ៣ ថា*

**នេវ សាលោ ន ខទិរោ, នាស្សកណ្ណោ កុតោ ធវោ;**
**រុក្ខោ ច ផន្ទនោ នាម, តំ ទារុំ នេមិយា ទឡ្ហំ។**

***ដើមរាំងក៏មិនជាប់ ដើមគគីរក៏មិនជាប់ ដើមត្រចៀកប្រើសក៏មិនជាប់ ដើមត្របែកក៏មិនជាប់ មានតែដើមពង្រ ឈើនោះ ធ្វើកង់រទេះជាប់មាំ ។***

*វឌ្ឍកីព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ កើតសេចក្តីសោមនស្សថា ថ្ងៃនេះជាថ្ងៃល្អមែន យើងចូលព្រៃ ហើយមានសត្វតិរច្ឆានមកប្រាប់ឈើដែលសមគួរធ្វើរថដល់យើង ពិតជាប្រពៃណាស់ ដូច្នេះកាលនឹងសួរ ( ពីលក្ខណៈដើមពង្រ) ទើបពោលគាថាទី ៤ ថា*

**កីទិសានិស្ស បត្តានិ, ខន្ធោ វា បន កីទិសោ;**
**បុដ្ឋោ មេ សម្ម អក្ខាហិ, យថា ជានេមុ ផន្ទនំ។**

***ស្លឹកពង្រនោះ បែបដូចម្តេច ដើមពង្រនោះ បែបដូចម្តេច ម្នាលសម្លាញ់ យើងសួរហើយ អ្នកចូរប្រាប់ យើងគប្បីស្គាល់ដើមពង្រ យ៉ាងណា ។***

លំដាប់នោះ ខ្លាឃ្មុំកាលនឹងប្រាប់ជាងឈើ ទើបពោល ២ គាថាថា

យស្ស សាខា បលម្ពន្តិ,　　　　នមន្តិ ន ច កញ្ជរេ;
សោ រុក្ខោ ជង្ឃជោ ជាម,　　　　យស្ស មូលេ អហំ ឋិតោ។

មែកឈើណា សំយុងចុះផង ទន់ទោរផង មិនបាក់ផង ខ្ញុំឈរក្បែរគល់ឈើណា ឈើនោះហើយ ជាដើមពន្ល៍ ។

អរានំ ចក្កនាភីនំ,　　　　ឦសានេមិរថស្ស ច;
សព្ពស្ស តេ កម្មនិយោ,　　　　អយំ ហេស្សតិ ជង្ឃជោ។

ដើមពន្ល៍នេះ គួរដល់ការងាររបស់អ្នក ដើម្បីកាំរទេះទាំងឡាយ ដើម្បីកង់ និងដុំរទេះទាំងឡាយ ដើម្បីចន្ទោលរទេះ និងខ្នងកង់រទេះ និងរបស់សព្វគ្រប់ ក្រៅពីនេះទាំងអស់ ។

កាឡសីហៈប្រាប់យ៉ាងនេះហើយ មានចិត្តត្រេកអរ ដើរត្រាច់ទៅកាន់ទីកន្លែងមួយ ចំណែកវឌ្ឍកីព្រាហ្មណ៍ក៏ប្រារព្ធដើម្បីកាត់ដើមពន្ល៍នោះ ។ រុក្ខទេវតាគិតថា យើងមិនបានឲ្យអ្វីៗធ្លាក់លើខ្លាឃ្មុំនេះទេ ខ្លាឃ្មុំនេះចងអាឃាតក្នុងហេតុដែលមិនគួរ ញុំាងវិមានរបស់យើងឲ្យវិនាស សូម្បីយើងក៏ត្រូវវិនាស យើងនឹងឲ្យខ្លាឃ្មុំនេះវិនាស ដោយឧបាយយ៉ាងណាមួយដែរ ។ រុក្ខទេវតាក៏ក្លែងខ្លួន ធ្វើដូចជាបុរសអ្នកធ្វើការងារក្នុងព្រៃ ដើរទៅកាន់សម្នាក់ជាងឈើនោះសួរថា នែបុរសដ៏ចម្រើន លោកបានដើមឈើជាទីពេញចិត្ត កាត់ដើមឈើនេះហើយ លោកនឹងធ្វើអ្វីទៀត ? ជាងឈើពោលថា ខ្ញុំនឹងធ្វើខ្នងកង់រថ ។ រុក្ខទេវតាសួរទៀតថា ចុះអ្នកណាប្រាប់លោកថា រថនឹងធ្វើដោយដើមឈើនេះ ។ ជាងឈើពោលថា គឺកាឡសីហៈមួយ ។ រុក្ខទេវតាពោលថា ល្អហើយចឹង បើខ្លាឃ្មុំនោះប្រាប់លោក រថដែលល្អប្រសើរត្រូវធ្វើដោយដើមឈើនេះ លោកចូរគ្រៀលស្បែកបំពង់កខ្លាឃ្មុំ មករុំមណ្ឌលខ្នងកង់ក្នុងទីប្រមាណ ៤ ធ្នាប់ ហាក់ដូចជាធ្វើដោយបន្ទះដែក ធ្វើយ៉ាងនេះ ខ្នងកង់នឹងមាំមួន អ្នកនឹងបានទ្រព្យច្រើន ។ ជាងឈើសួរថា ខ្ញុំនឹងបានស្បែកខ្លាឃ្មុំអំពីណា ? រុក្ខទេវតាពោលថា អ្នកជាមនុស្សល្ងង់ ដើម

ឈើរបស់អ្នកនេះ បិតនៅក្នុងព្រៃ មិនរត់ទៅណាទេ ខ្ញាឃ្មុំណាប្រាប់ដើមឈើនេះដល់អ្នក អ្នកចូរទៅកាន់សម្នាក់ខ្ញាឃ្មុំនោះ ហើយបញ្ឆោតវាថា បពិត្រលោកម្ចាស់ ដើមឈើដែលលោកប្រាប់ដល់ខ្ញុំនោះ ខ្ញុំបានកាត់ទុកនៅត្រង់កន្លែងមួយ រួចអ្នកចូរនាំខ្ញាឃ្មុំនោះមក ពេលនោះវាមិនមានសេចក្តីសង្ស័យនឹងអ្នកទេ អ្នកចូរនិយាយថា នឹងកាត់ត្រង់នេះត្រង់នោះ ដូច្នេះកាលកំពុងប្រាប់ អ្នកចូរកាប់វាដោយពូថៅធំដ៏មុត ធ្វើវាឲ្យអស់ជីវិត ហើយកាន់យកស្បែក និងស៊ីសាច់ល្អៗ រួចសឹមកាត់ដើមឈើនេះចុះ ដូច្នេះហើយ រុក្ខទេវតាក៏បានញ៉ាំងពៀរឲ្យសម្រេច ។

ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាទាំងនេះថា

ឥតិ ផន្ទន រុក្ខាបិ, តាវទេ អជ្ឈភាសថ;
មយ្ហម្បិ វចនំ អត្ថិ, ភារទ្វាជ សុណោហិ មេ។

ព្រោះហេតុនោះ ទេវតាអាស្រ័យនៅលើដើមពង្រ បាននិយាយថា ពាក្យរបស់ខ្ញុំក៏មានដែរ ម្នាលភារទ្វាជព្រាហ្មណ៍ អ្នកឯងចូរស្តាប់ពាក្យខ្ញុំសិន ។

ឥស្សស្ស ឧបក្ខន្ធម្ហា, ឧក្កច្ច ចតុរង្គុលំ;
តេន នេមិំ បសារេសិ, ឯវំ ទឡ្ហតរំ សិយា។

អ្នកចូរអារយកស្បែកខ្ញាឃ្មុំនេះ ត្រង់ក ចំនួន ៤ ធ្នាប់ ហើយយកស្បែកនោះមកទ្រាប់ខ្នងកង់រទេះ ធ្វើយ៉ាងនេះ ទើបជាប់មាំមួន ។

ឥតិ ផន្ទន រុក្ខាបិ, វេរំ អប្បេសិ តាវទេ;
ជាតានញ្ច អជាតានំ, ឥស្សានំ ទុក្ខមាវហិ។

*ទេវតាដែលអាស្រ័យនៅលើដើមពង្រ បានសម្រេចពៀរហើយ បាននាំយកសេចក្ដីទុក្ខមកឲ្យដល់ខ្លាឃ្មុំទាំងឡាយ ដែលកើតហើយផង ដែលមិនទាន់កើតហើយផង ដោយប្រការដូច្នេះ ។*

*វឌ្ឍកីព្រាហ្មណ៍ស្ដាប់ពាក្យរុក្ខទេវតាហើយ គិតថា ឱហ្ន៎ ថ្ងៃនេះជាថ្ងៃមង្គលរបស់យើងដូច្នេះហើយ គាត់ក៏បានសម្លាប់ខ្លាឃ្មុំ និងកាត់ដើមពង្រ រួចចៀសចេញទៅ ។*

*ព្រះសាស្ដាកាលប្រកាសសេចក្ដីនោះ ទើបត្រាស់ថា*

ឥច្ចេវ ផន្ទនោ ឥស្សំ, ឥស្សោ ច បន ផន្ទនំ;
អញ្ញមញ្ញំ វិវាទេន, អញ្ញមញ្ញមឃាតយុំ។

*ដើមពង្រចងពៀរនឹងខ្លាឃ្មុំ ឯខ្លាឃ្មុំចងពៀរនឹងដើមពង្រ ហើយបានសម្លាប់គ្នាទៅវិញទៅមក ដោយការទាស់ទែងគ្នាទៅវិញទៅមក ដោយប្រការដូច្នេះឯង ។*

ឯវមេវ មនុស្សានំ, វិវាទោ យត្ថ ជាយតិ;
មយូរនច្ចំ នច្ចន្តិ, យថា តេ ឥស្សផន្ទនា។

*ខ្លាឃ្មុំ និងដើមពង្រនោះ ចងពៀរវេរាយ៉ាងណា ការទាស់ទែងរបស់មនុស្សទាំងឡាយកើតមានក្នុងទីណា មនុស្សទាំងនោះ ឈ្មោះថា រាំដូចជាក្ងោកពង់ ក្នុងទីនោះ ក៏យ៉ាងនោះដែរ ។*

តំ វោ វទាមិ ភទ្ទំ វោ, យាវន្តេត្ថ សមាគតា;
សម្មោទថ មា វិវទថ, មា ហោថ ឥស្សផន្ទនា។

*តថាគតនឹងសំដែងនូវហេតុនោះថ្វាយមហារាជ ពួកមនុស្សដែលមកប្រជុំក្នុងទីនេះមានចំនួនប៉ុន្មាន សូមសេចក្ដីចម្រើនមានដល់មហាបពិត្រ មានចំនួនប៉ុណ្ណោះ សូមមហាបពិត្រព្រមព្រៀងគ្នា កុំទាស់ទែងគ្នា កុំឲ្យដូចខ្លាឃ្មុំ និងដើមពង្រឡើយ ។*

**សាមគ្គិមេវ សិក្ខេថ, ពុទ្ធេហេតំ បសំសិតំ;**
**សាមគ្គិរតោ ធម្មដ្ឋោ, យោគក្ខេមា ន ធំសតិ។**

*សូមមហាបពិត្រ សិក្សានូវសេចក្តីព្រមព្រៀងគ្នាតែម៉្យាង ព្រោះសេចក្តីព្រមព្រៀងគ្នានោះ ព្រះពុទ្ធទាំងឡាយសរសើរហើយ បុគ្គលអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀងគ្នា អ្នកតាំងនៅក្នុងធម៌ រមែងមិនសាបសូន្យចាកព្រះនិព្វានជាទីក្សេម ចាកយោគៈទាំងឡាយឡើយ ។*

*ពួកសក្យរាជទាំងឡាយបានស្តាប់ធម្មកថាហើយ ក៏កើតសេចក្តីសាមគ្គីឡើង ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា*

**តទា តំ ការណំ វិទិត្វា តស្មិំ វនសណ្ឌេ និវុត្ថទេវតា អហមេវ អហោសិំ** *ទេវតាដែលនៅក្នុងព្រៃ បានដឹងហេតុការណ៍ ក្នុងកាលនោះ គឺ តថាគតនេះឯង ។*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តេរសកនិបាត បិដកលេខ ៥៩ ទំព័រ ២៧០)*

*ថ្ងៃ សៅរ៍ ៨ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២៨ ខែ កក្កដា ព.ស. ២៥៦២ គ.ស.២០១៨*
*ដោយស.ដ.វ.ថ*